**3/6 DRH All-Staff and Families Email Update**

**(for staff)** ជូនចំពោះបុគ្គលិក៖

**(for families)** ជូនចំពោះក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ជាទីគោរព៖

ស្ថានភាពនៃជម្ងឺ មេរោគខូរូណា កំពុងតែប្រែប្រួលយ៉ាងឆាប់រហ័សនៅសហរដ្ឋអាមេរិកនេះ។ ខ្ញុំសរសេរសារនេះ ដើម្បីផ្ដល់ការរំឭកដ៏សំខាន់អំពីអ្វីដែលយើងទាំងអស់គ្នាអាចធ្វើដើម្បីត្រៀម និងផ្ដល់ជូនលោកអ្នកនូវវិធានការបន្ថែមទៀត ដែលយើងកំពុងអនុវត្តដើម្បីគាំទ្រដល់ សាលា និង បរិស្ថានការងារ ដែលប្រកបដោយសុខភាព។

**នៅពេលនេះ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) គ្មានករណី សង្ស័យ ឬ ដឹងច្បាស់ ថាមានផ្ទុកមេរោគខូរូណានេះនៅក្នុង សាលារៀន ឬ ការិយាល័យ ទេ។**

អ្វីដែលសំខាន់បំផុត ដែលយើងអាចធ្វើដើម្បីការពារ ខ្លួនយើង និង អ្នកដទៃ គឺត្រូវបន្តអនុវត្តសកម្មភាពបង្ការជាមូលដ្ឋានទាំងនេះ៖

- លាងដៃរបស់លោកអ្នកជាមួយ សាប៊ូ និង ទឹក យ៉ាងហោចណាស់ ២០ វិនាទី ជាប្រចាំ
- ក្អក ឬ កណ្ដាស់ ដាក់ដៃ ឬ បិត ច្រមុះ និង មាត់ របស់លោកអ្នកជាមួយក្រដាសជូតច្រមុះ នៅពេលលោកអ្នក ក្អក ឬ កណ្ដាស់ – រួចហើយលាងដៃរបស់លោកអ្នក
- ចៀសវាងដាក់ម្រាមដៃចូលក្នុង មាត់ ច្រមុះ ឬ ភ្នែក របស់លោកអ្នក
- កុំចេញពីផ្ទះ បើសិនជាលោកអ្នកឈឺ

វិធានការផ្សេងៗទៀតដែលក្រសួងអប់រំអនុវត្ត ដើម្បីកាត់បន្ថយការរីករាលដាលនៃមេរោគខូរូណា រួមមាន៖

- **បន្ថែម អាកុលលាងដៃ (hand sanitizer) និង ក្រដាសជូតសម្លាប់មេរោគ (sanitizing wipes)** - សម្ភារៈទាំងនេះគេបានផ្ដល់ទៅឱ្យតាមសាលានៅថ្ងៃនេះ ថ្ងៃសុក្រ ទី ៦ ខែមីនា ហើយនឹងត្រូវគេផ្ដល់ឱ្យប្រើប្រាស់ស្របទៅតាមអនុសាសន៍របស់ក្រសួងសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PDPH)។ សាលាត្រូវរៀបចំដាក់អាកុលលាងដៃ នៅតាមផ្លូវចូល និង ក្នុងសាលញ៉ាំបាយ សម្រាប់ការប្រើប្រាស់ជាញឹកញាប់របស់ សិស្ស បុគ្គលិក និង អ្នកដែលមកកាន់សាលា។ គ្រូ និង សិស្ស អាចប្រើក្រដាសជូតនៅក្នុងថ្នាក់រៀន ទៅតាមការដែលមានសម្ភារៈ។
- **អនុវត្តការសម្អាតបន្ថែមទៀត** - វិធីសម្អាតយ៉ាងមុតមាំរបស់យើង ត្រូវបានកែលម្អ ហើយ បុគ្គលិកបោសសម្អាត និង វិស្វករប្រចាំអាគារ នឹងយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការសម្អាត និង សម្លាប់មេរោគ នៅតាមកន្លែងដែលគេប៉ះពាល់ជាញឹកញាប់ តាមបង្កាន់ដៃជណ្ដើរ ដៃទ្វារ និង តុ។

យើងបានដឹងថា មានភាពមិនច្បាស់លាស់ និង ការភ័យព្រួយ ជាច្រើន ដែលទាក់ទងនឹងមេរោគខូរូណានេះ។ សូមជ្រាបថា យើងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើស្ថានភាពនេះ។ យើងនឹងបន្តតាមដានព័ត៌មានពី មជ្ឈ

មណ្ឌល ត្រួតពិនិត្យ និង ទប់ស្កាត់ ជម្ងឺ ជារៀងរាល់ថ្ងៃ និង ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងសុខាភិបាល នៃទីទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PDPH) និង ការិយាល័យគ្រប់គ្រងគ្រោះអាសន្ន របស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដើម្បីឱ្យដឹងពីព័ត៌មានទាន់សភាពការណ៍ និង ទទួលការណែនាំ។

ដើម្បីងាយទទួលបានព័ត៌មាន និង ប្រភពជំនួយ ថ្មីៗអំពីមេរោគខូរូណា សូមចូលមើលវ៉ិបសៃ www.philasd.org/coronavirus ។ ខ្ញុំនឹងបន្តជូនដំណឹងដល់លោកអ្នកអំពីផែនការរបស់យើង។

ដោយសេចក្តីគោរពរាប់អាន

*(Bill signature here)*

William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា